ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# និយាមនៃបែបបទសំរាប់

# អនុវត្តសកម្មភាពថែទាំនៅ

# មណ្ឌលមិត្តជួយមិត្ត

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ


បោះពុម្ពលើកទី១. ខែ មេសា ឆ្នាំ ២០០៦

ចំនួន ៥០០ ច្បាប់

**និយាមនៃបែបបទ**

**សំរាប់**

**អនុវត្តសកម្មភាពនៅមណ្ឌលមិត្តជួយមិត្តនៃព្រះរាជាណាចក្រកម្ពុជា**

## ១. ប្រវត្តិ និងសនិទានភាព (Background and rationale)

នៅក្នុងឆ្នាំ ២០០៣ មនុស្សពេញវ័យដែលមានអាយុពី ១៥-៤៩ ឆ្នាំ ចំនួន ១២៣.១០០នាក់ ត្រូវបានគេប៉ាន់ស្មានថាបានផ្ទុកមេរោគអេដស៍ ដែលក្នុងនោះមានប្រហែល ២០.០០០នាក់ ជាអ្នកជំងឺអេដស៍ដែលកំពុងត្រូវការចាំបាច់នូវការថែទាំព្យាបាល ។

ដោយមានការកើនឡើងនូវតំរូវការនៃការថែទាំព្យាបាលអ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ ក្រសួងសុខាភិបាលបានអនុម័តលើគំរោងសំណុំសកម្មភាពសំរាប់អនុវត្តការថែទាំព្យាបាលបន្តដល់អ្នកផ្ទុកមេរោគអេដស៍នៅក្នុងខែមេសាឆ្នាំ២០០៣ ។ ការថែទាំព្យាបាល និង គាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយត្រូវបានអនុម័តអោយអនុវត្ត ហើយត្រូវបានពង្រឹង និងពង្រីកជាបន្តបន្ទាប់ ។ រហូតមកដល់ខែធ្នូ ឆ្នាំ ២០០៥ មានអ្នកជំងឺអេដស៍ចំនួន ១២.៣៥៥នាក់ ដែលក្នុងនោះមានកុមារចំនួន ១០៧១នាក់ បានទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ នៅតាមមន្ទីរពេទ្យបង្អែក និង មន្ទីរពេទ្យជាតិចំនួន ៣២ កន្លែង ។ កិច្ចសហការរវាង កម្មវិធីជាតិផ្សេងៗ (កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍, កម្មវិធីកំចាត់រោគរបេង និងកម្មវិធីគាំពារមាតា និងទារក) ត្រូវបានពង្រឹង ។ សេវាថែទាំអ្នកជំងឺអេដស៍តាមផ្ទះ និងតាមសហគមន៍, ក្រុមគាំទ្រអ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ ត្រូវបានពង្រឹង និងពង្រីកនៅគ្រប់ខេត្ត-ក្រុង និងស្រុកប្រតិបត្តិទូទាំងប្រទេស ។

ទោះបីជាមានការកើនឡើងនូវសេវាថែទាំព្យាបាល និងគាំទ្រក៏ដោយ សំរាប់ប្រទេសដែលមានការខ្វះខាតនូវប្រភពធនធានដូចជាប្រទេសកម្ពុជា អ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ នៅតែជួបការលំបាកមួយចំនួនក្នុងការទទួលបានសេវាថែទាំព្យាបាលទាំងនេះ ជាពិសេស ខ្វះខាតថវិកា, និងខ្វះការគាំទ្រផ្នែកសង្គម និងចិត្តសាស្ត្រ ។

មណ្ឌលមិត្តជួយមិត្ត (MMM) គឺជាសកម្មភាពមួយសំខាន់នៃសំណុំសកម្មភាពថែទាំព្យាបាលបន្តដល់អ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ ។ សកម្មភាពនេះ ផ្តោតការយកចិត្តទុកដាក់ជាចំបងលើសកម្មភាពថែទាំអ្នកផ្ទុកមេរោគអេដស៍ និង អ្នកជំងឺអេដស៍ នៅក្នុងស្រុកប្រតិបត្តិ ។ បន្ថែមលើសេវាថែទាំសុខភាព សកម្មភាពនេះ ជាកត្តាជំរុញអោយមានការបង្កើតនូវសេវាផ្សេងៗទៀត ដូចជា ការគាំទ្រផ្នែកសង្គម និងការអប់រំតាមសហគមន៍ ហើយក៏ដើរតួជាកត្តាសំខាន់នាំអោយមានការបង្កើតគំនិតថ្មី ភាពជាអ្នកដឹកនាំ និង ភាពជាដៃគូក្នុងមូលដ្ឋាន ។

គំរូ (Model) នៃសកម្មភាពនៅមណ្ឌលមិត្តជួយមិត្ត (MMM) បានអនុវត្តនៅក្នុងស្រុកប្រតិបត្តិមួយចំនួន ដែលបានបង្ហាញឱ្យឃើញនូវការរួមចំណែកគួរឱ្យកត់សំគាល់ក្នុងការធ្វើអោយប្រសើរឡើងនូវសុខភាព និង សុខមាលភាពរបស់អ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ ។ ជាមួយនឹងការរីកចំរើននៃសេវាថែទាំសុខភាព និងការពង្រឹងភាពជាដៃគូនៅថ្នាក់ស្រុកប្រតិបត្តិ តួនាទីរបស់មណ្ឌលមិត្តជួយមិត្ត នៅក្នុងមន្ទីរពេទ្យបង្អែក ត្រូវការពង្រីកបន្ថែមទៀតដើម្បីអោយការផ្តល់សេវាបានទូលំទូលាយ ។

## ២. គោលបំណង

និយាមនៃបែបបទសំរាប់អនុវត្ត (Standard Operating Procedure) នេះ មានគោលបំណងផ្តល់ការណែនាំដល់អ្នកផ្តល់សេវាថែទាំសុខភាពសាធារណៈ និងដៃគូការងារពាក់ព័ន្ធផ្សេងៗ ជាពិសេស បណ្តាញអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា (CPN+) ដែលទទួល

បន្ទុកក្នុងការរៀបចំឱ្យដំណើរការមណ្ឌលមិត្តជួយមិត្តដែលមានចែងក្នុងសំណុំសកម្មភាពថែទាំព្យាបាលបន្តដល់អ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ នៅក្នុងប្រទេសកម្ពុជា ហើយក៏ជាផ្នែកមួយក្នុងការពង្រីកការទទួលបានជាសកលនូវសេវាបង្ការ ថែទាំព្យាបាល និងគាំទ្រ ។ និយាមនៃបែបបទសំរាប់អនុវត្តនេះ បានបង្ហាញពីជំហានក្នុងការបង្កើតមណ្ឌលមិត្តជួយមិត្តនៅថ្នាក់ស្រុកប្រតិបត្តិ និងបញ្ជាក់នូវសំណុំសកម្មភាពដែលអាចផ្តល់អោយដោយមណ្ឌលមិត្តជួយមិត្ត ។ ទោះជាយ៉ាងណាក៏ដោយ ឯកសារនេះត្រូវតែមានការកែសំរួលជាទៀងទាត់ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរស្ថានការណ៍ និងតំរូវការរបស់អ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ ដោយផ្អែកលើអនុសាសន៍របស់អនុគណៈកម្មការសំរបសំរួលការងារថែទាំព្យាបាលតាមមន្ទីរពេទ្យ (Health Facility-Based Care Sub-Committee) ។

## ៣. ជំហានក្នុងការបង្កើតមណ្ឌលមិត្តជួយមិត្ត

### ៣.១. ការប៉ាន់ស្មានតំរូវការ និងដំណើរការនៃការធ្វើផែនការជំហានដំបូង (Need assessment and initial planning process)

ការប៉ាន់ស្មានតំរូវការនៃមណ្ឌលមិត្តជួយមិត្ត គប្បីធ្វើឡើងជាមួយការប៉ាន់ប្រមាណលើតំរូវការសេវាថែទាំព្យាបាលបន្តដល់អ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ ដែលធ្វើឡើងដោយអ្នកសំរបសំរួលកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ថ្នាក់ស្រុកប្រតិបត្តិ ដោយមានការជួយគាំទ្រពីកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត-ក្រុង និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ហើយផ្តោតលើចំណុចសំខាន់៧ដូចខាងក្រោម :

- ទំហំ (scope) នៃបញ្ហាជំងឺអេដស៍នៅក្នុងស្រុកប្រតិបត្តិ : ធ្វើការប៉ាន់ស្មានចំនួនអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍
- កំណត់ទីតាំងដែលសមស្របសំរាប់ធ្វើជាមណ្ឌលមិត្តជួយមិត្តនៅក្នុងមន្ទីរពេទ្យបង្អែក (តើមានអាគារសំរាប់ប្រើប្រាស់ជាមណ្ឌលមិត្តជួយមិត្តឬទេ? ត្រូវសាងសង់ថ្មី ឬ ជួសជុល?, តើត្រូវការទំហំប៉ុណ្ណា ។ល។) មជ្ឈមណ្ឌលជាតិបានរៀបចំនូវគំរូប្លង់អាគារ MMM និង សេវា OI/ART ។
- កំណត់សមាជិកសំរាប់ធ្វើការនៅមណ្ឌលមិត្តជួយមិត្ត
- កំណត់តំរូវការរបស់អ្នកផ្ទុកមេរោគអេដស៍
- ប្រភពធនធានដែលត្រូវការ / ប៉ាន់ស្មានតំរូវការថវិកា
- កំណត់ភាគីដៃគូការងារ និង ដៃគូដែលអាចផ្តល់ការគាំទ្រដល់ដំណើការនៃមណ្ឌលមិត្តជួយមិត្ត

របាយការណ៍នៃការប៉ាន់ស្មាន (ការរកឃើញបញ្ហាផ្សេងៗ និងការផ្តល់អនុសាសន៍) នឹងត្រូវបង្ហាញ ពិភាក្សា និងអនុម័ត ដោយគណៈកម្មការសំរបសំរួលសេវាថែទាំព្យាបាលបន្តដល់អ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ថ្នាក់ស្រុកប្រតិបត្តិ ដែលរួមមានដៃគូការងារទាំងអស់ តំណាងអ្នកផ្ទុកមេរោគអេដស៍ និងបណ្តាញអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា (CPN+) ។ គំរោងផែនការសំរាប់អនុវត្តសកម្មភាពដែលរួមមានគំរោងថវិកា នឹងត្រូវរៀបចំឡើងទៅតាមអនុសាសន៍របស់គណៈកម្មការសំរបសំរួលសេវាថែទាំព្យាបាលបន្តដល់អ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ថ្នាក់ស្រុកប្រតិបត្តិ ។ កំណត់ហេតុនៃកិច្ចប្រជុំដែលមានទាំងការរកឃើញបញ្ហាផ្សេងៗ និងអនុសាសន៍អំពីការប៉ាន់ស្មាននេះ នឹងត្រូវដាក់ជូនមជ្ឈមណ្ឌលជាតិពិនិត្យ តាមរយៈមន្ទីរសុខាភិបាល និងកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ។

### ៣.២. ការអនុវត្តន៍សកម្មភាពមណ្ឌលមិត្តជួយមិត្ត

ការអនុវត្តន៍សកម្មភាពមណ្ឌលមិត្តជួយមិត្ត គប្បីធ្វើឡើងដោយបណ្តាញអ្នកផ្ទុកមេរោគអេដស៍នៅថ្នាក់ស្រុកប្រតិបត្តិ (DPN+) និងអ្នកផ្ទុកមេរោគអេដស៍ខ្លួនឯង ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងរយៈពេលបណ្តោះអាសន្ន ការបង្កើត និងការអនុវត្តន៍សកម្មភាព

មណ្ឌលមិត្តជួយមិត្ត អាចធ្វើឡើងដោយបុគ្គលិកសុខាភិបាល សហការជាមួយបណ្តាញអ្នកផ្ទុកមេរោគអេដស៍នៅថ្នាក់ស្រុកប្រតិបត្តិ ។ អ្នកសំរបសំរួលកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ថ្នាក់ស្រុកប្រតិបត្តិ នឹងទទួលខុសត្រូវក្នុងការបង្កើតមណ្ឌលមិត្តជួយមិត្តនៅក្នុងស្រុកប្រតិបត្តិរបស់ខ្លួនដោយធ្វើការពិគ្រោះយោបល់ជាមួយគណៈ កម្មការសំរបសំរួលសេវាថែទាំព្យាបាលបន្តដល់អ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ថ្នាក់ស្រុកប្រតិបត្តិ និងត្រូវគោរពទៅតាមនិយាមនៃបែបបទសំរាប់អនុវត្តសកម្មភាពមណ្ឌលមិត្តជួយមិត្តនេះ ។

### ៣.២.១. ការបង្កើត និងទីតាំងរបស់មណ្ឌលមិត្តជួយមិត្ត

- ដើម្បីធានាអោយមាននិរន្តភាពនៃសេវានៅមណ្ឌលមិត្តជួយមិត្ត និងដើម្បីធានាថា អ្នកផ្ទុកមេរោគអេដស៍អាចទទួលបាននូវសេវាផ្សេងៗ រួមមានសេវាថែទាំសុខភាព និងសេវាគាំទ្រផ្សេងៗទៀត មណ្ឌលមិត្តជួយមិត្តគប្បីមានទីតាំងនៅក្នុងបរិវេណរបស់មន្ទីរពេទ្យបង្អែក ឬ អតីតមន្ទីរពេទ្យស្រុក ។
- ចំពោះទីតាំងពិតប្រាកដរបស់មណ្ឌលមិត្តជួយមិត្តគប្បីពិភាក្សាអោយល្អិតល្អន់ជាមួយគ្រប់ដៃគូការងារទាំងអស់ និងត្រូវមានការយល់ព្រមពីគណៈកម្មការសំរបសំរួលសេវាថែទាំព្យាបាលបន្តដល់អ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ថ្នាក់ស្រុកប្រតិបត្តិ ដើម្បីធានាថាទីតាំងនេះសមស្របសំរាប់សេវាទាំងឡាយដែលពាក់ព័ន្ធ ។
- អាគារសមស្របដែលមានបន្ទប់ទំនេរ គប្បីរៀបចំសំរាប់សកម្មភាពមណ្ឌលមិត្តជួយមិត្ត ឬ ត្រូវជួសជុលបន្ទប់ដែលមានស្រាប់បើចាំបាច់ ។ អាគារថ្មី នឹងអាចត្រូវសាងសង់ឡើងបើពុំមានបន្ទប់ទំនេរសំរាប់រៀបចំមណ្ឌលមិត្តជួយមិត្តទេ ។ ទំហំរបស់មណ្ឌលមិត្តជួយមិត្ត គប្បីកំណត់ដោយយោងតាមការប៉ាន់ស្មានករណីជំងឺអេដស៍នៅស្រុកប្រតិបត្តិ ។ នៅទីណាដែលមានសេវាព្យាបាលកុមារផ្ទុកមេរោគអេដស៍នៅផ្នែកជំងឺកុមារនៃមន្ទីរពេទ្យបង្អែក គប្បីរៀបចំបន្ទប់មួយបន្ថែមទៀតដើម្បីជាជំនួយដល់សកម្មភាពមណ្ឌលមិត្តជួយមិត្តសំរាប់កុមារ ។
- ការសាងសង់អាគារថ្មី ឬ ក៏ជួសជុល គប្បីសុំការអនុម័តពីស្រុកប្រតិបត្តិ, មន្ទីរសុខាភិបាលខេត្ត, មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងក្រសួងសុខាភិបាលជាមុនសិន ។

### ៣.២.២. សមាជិកភាព និងការទទួលខុសត្រូវរបស់ក្រុមការងារនៃមណ្ឌលមិត្តជួយមិត្ត

សមាជិកធ្វើការនៅមណ្ឌលមិត ្តជួយមិត្តរួមមាន :

- អ្នកសំរបសំរួលម្នាក់ ដែលជាសមាជិករបស់បណ្តាញអ្នកផ្ទុកមេរោគអេដស៍ថ្នាក់ស្រុក (DPN+) ។ បើពុំមានបណ្តាញអ្នកផ្ទុកមេរោគអេដស៍ថ្នាក់ស្រុកទេ ត្រូវជ្រើសរើសអ្នកផ្ទុកមេរោគអេដស៍ម្នាក់ចេញពីក្រុមគាំទ្រក្នុងស្រុកប្រតិបត្តិ អោយធ្វើជាអ្នកសំរបសំរួលការងារនេះ
- អ្នកជំនួយការម្នាក់ដែលជាអ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ នៅក្នុងក្រុមគាំទ្រក្នុងស្រុកប្រតិបត្តិ (ប្រសិនបើចាំបាច់អាចមានអ្នកជំនួយការពីរនាក់)

| **សមាជិក** | ***ភារកិច្ច / ការទទួលខុសត្រូវ*** |
|---|---|
| អ្នកសំរបសំរួល | - ធ្វើការសំរបសំរួលរាល់ការងារទាំងអស់របស់មណ្ឌលមិត្តជួយមិត្ត<br>- ជាសមាជិករបស់គណៈកម្មការសំរបសំរួលសេវាថែទាំព្យាបាលបន្តដល់អ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ថ្នាក់ស្រុកប្រតិបត ្តិ<br>- រៀបចំសកម្មភាពប្រជុំប្រចាំខែរបស់សកម្មភាពមណ្ឌលមិត្តជួយមិត្ត រួមមាន ការសំរបសំរួលការ |

| | |
|---|---|
| | ប្រជុំ ការរៀបចំរបៀបវារៈនៃការប្រជុំ និងការរក្សាទុកឯកសារផ្សេងៗ<br>- ធ្វើការផ ្តល់ប្រឹក្សាគាំទ្រ<br>- ធ្វើការបញ្ជូនអ្នកជំងឺទៅកាន់សេវាផ្សេងៗ ដែលសមស្រប<br>- ជួយក្នុងការចុះឈ្មោះ និងរៀបចំឯកសារសំរាប់អ្នកជំងឺ |
| អ្នកជំនួយការ<br>(អាចមានម្នាក់ ឬ ពីរនាក់) | ចូលរួមក្នុងការអនុវត្តន៏ការងាររបស់មណ្ឌលមិត្តជួយមិត្តទៅតាមការណែនាំរបស់អ្នកសំរបសំរួលដែលរួមមាន :<br>- រៀបចំកិច្ចប្រជុំប្រចាំខែ<br>- ធ្វើការផ្តល់ប្រឹក្សាជាក្រុម ឬ ជាបុគ្គល<br>- រៀបចំមណ្ឌលមិត្តជួយមិត្តសំរាប់កុមារ<br>- ធ្វើការបញ្ជូនអ្នកជំងឺទៅកាន់សេវាផ្សេងៗ ដែលសមស្រប<br>- ធ្វើការទាក់ទង និងបញ្ជូនអ្នកជំងឺទៅក្រុមគាំទ្រ និងសេវាគាំទ្រផ្សេងៗទៀត |

សមាជិកក្រុមការងារនៅមណ្ឌលមិត ្តជួយមិត្ត ត្រូវស្នើឡើងដោយបណ ្តាញអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជាថ្នាក់ជាតិ ឬថ្នាក់ខេត ្ត និងត្រូវជ្រើសរើសដោយគណៈកម្មការសំរបសំរួលសេវាថែទាំព្យាបាលបន្តដល់អ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ថ្នាក់ស្រុកប្រតិបត ្តិ ហើយឈ្មោះសមាជិកទាំងនោះ ត្រូវបញ្ជូនមកមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ។ នៅពេលចាប់ផ្តើម ដំណើរការ MMM គប្បីជ្រើសរើសបុគ្គលិកមន្ទីរពេទ្យបង្អែកម្នាក់អោយជួយក្នុងការរៀបចំសកម្មភាពមណ្ឌលមិត ្តជួយមិត្ត ។ បញ្ជីឈ្មោះ សមាជិកក្រុម និងពតិមានសំរាប់ទំនាក់ទំនងនៅមណ្ឌលមិត ្តជួយមិត្ត ត្រូវចែកចាយអោយដៃគូការងារទាំងអស់ដើម្បីសហការការងារនាពេលអនាគត ។

សមាជិកក្រុម គប្បីទទួលបានការបណ្តុះបណ្តាលអំពីចំណេះដឹង និងជំនាញផ្សេងៗដែលចាំបាច់សំរាប់អនុវត្តសកម្មភាពមណ្ឌលមិត្តជួយមិត្តទៅតាមភារកិច្ចរបស់ពួកគេ ។ ការបណ្តុះបណ្តាល គប្បីធ្វើឡើងដោយអ្នកសំរបសំរួលកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ថ្នាក់ស្រុកប្រតិបត្តិ ដោយមានជំនួយបច្ចេកទេសពីមន្ត្រីកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត-ក្រុង និងសហការជាមួយដៃគូការងារពាក់ព័ន្ធផ្សេងៗទៀតដែលបំរើការងារនៅក្នុងស្រុកប្រតិបត្តិ ។ ការចុះពិនិត្យផ្ទាល់ដល់មណ្ឌលមិត្តជួយមិត្តដ៏ទៃទៀត អាចធ្វើឡើងជាផ្នែកមួយនៃការពង្រឹងសមត្ថភាព ។ ការចែករំលែកបទពិសោធន៏នៅមណ្ឌលមិត្តជួយមិត្ត អាចធ្វើឡើងជាផ្នែកមួយនៃការប្រជុំធំរបស់មណ្ឌលមិត្តជួយមិត្តប្រចាំឆ្នាំរបស់ខេត្ត-ក្រុង ។

ពតិមានស្តីអំពីទីកន្លែង, ពេលម៉ោងធ្វើការ និងប្រភេទសេវាដែលផ្តល់ជូននៅមណ្ឌលមិត្តជួយមិត្ត គប្បីធ្វើការផ្សព្វផ្សាយដល់ដៃគូការងារទាំងអស់ និងសហគមន៏ តាមរយៈបណ្តាញដែលមានស្រាប់ (គណៈកម្មការសំរបសំរួលសេវាថែទាំព្យាបាលបន្តដល់អ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ថ្នាក់ស្រុកប្រតិបត្តិ, ក្រុមថែទាំតាមផ្ទះ, ក្រុមគាំទ្រ) មុននឹងបើកដំណើរការមណ្ឌលមិត្តជួយមិត្ត ។

## ៤. សំណុំសកម្មភាពរបស់មណ្ឌលមិត្តជួយមិត្ត

សកម្មភាពខាងក្រោមនេះ អាចអនុវត្តនៅមណ្ឌលមិត្តជួយមិត្ត ក្នុងពេលប្រជុំ និងចន្លោះពេលប្រជុំ:

- សកម្មភាពមិត្តគាំទ្រមិត្ត

- ការអប់រំសុខភាពសំរាប់អ្នកផ្ទុកមេរោគអេដស៍ និងគ្រួសារអំពីការថែទាំខ្លួនឯង, ការថែទាំនៅតាមផ្ទះ, ការលើកកំពស់សុខភាព, អាហារូបត្ថម្ភ និងការបង្ការការចំលងមេរោគអេដស៍
- ការផ្តល់ប្រឹក្សាគាំទ្រ និងផ្តល់ប្រឹក្សាអោយមានការប្រើប្រាស់ឱសថប្រឆាំងនឹងមេរោគអេដស៍អោយបានជាប់លាប់និងត្រឹមត្រូវសំរាប់អ្នកផ្ទុកមេរោគអេដស៍ ដែលកំពុងព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ។ ការផ្តល់ប្រឹក្សានេះ គប្បីអនុវត្ត ជា បុគ្គល និងជាក្រុម
- ការគាំទ្រផ្នែកស្មារតី ដូចជា សូត្រធម៌បន់ស្រន់ និងការធ្វើសមាធិជាមួយព្រះសង្ឃ
- កម្មវិធីហាត់ប្រាណ
- ការបញ្ជូនទៅសេវាព្យាបាលជំងឺឱកាសនិយម និងសេវាព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍នៅក្នុងមន្ទីរពេទ្យបង្អែកដើម្បី :
    - ស្រាវជ្រាវរកជំងឺឱកាសនិយម រួមមានទាំងជំងឺរបេងផងដែរ
    - ពិនិត្យសុខភាព រួមមាន ការព្យាបាលជំងឺឱកាសនិយម
    - ទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍
- ការបញ្ជូនអ្នកជំងឺជាស្ត្រីទៅសេវាបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន និងសេវាគាំពារមាតា និងទារក ដ៏ទៃទៀត ដូចជា សេវាពន្យាកំណើត
- ការសំរបសំរួលនៅក្នុងការបញ្ជូនអ្នកជំងឺទៅកាន់ :
    - សេវាការគាំទ្រផ្នែកថវិកា និងសង្គម
    - សេវាលើកកំពស់ការងារ និងការរកប្រាក់ចំណូល
    - សេវាគាំទ្រដល់ក្មេងកំព្រា

### ៤.១.ការប្រជុំធំប្រចាំឆ្នាំរបស់មណ្ឌលមិត្តជួយមិត្តថ្នាក់ខេត្ត

ការប្រជុំធំនៃមណ្ឌលមិត្តជួយមិត្តថ្នាក់ខេត អាចរៀបចំនៅក្នុងខេត្តនិមួយៗរៀងរាល់ពីរឆ្នាំ ដើម្បីអោយសហគមន៍ទទួលពត៌មានអំពីបញ្ហា អេដស៍ ដើម្បីគាំទ្រដល់ការបង្ការ និងថែទាំជំងឺអេដស៍ និងដើម្បីរួមចំណែកកាត់បន្ថយការរើសអើងចំពោះអ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺ អេដស៍បន្ថែមទៀត ។ ការប្រជុំនេះនឹងត្រូវរៀបចំឡើងក្នុងថ្ងៃប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ហើយត្រូវសំរបសំរួលដោយ មន្ទីរសុខាភិបាលខេត្ត សហការជាមួយដៃគូផ្សេងៗទៀត និងមានការគាំទ្រផ្នែកបច្ចេកទេស និងថវិកាពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ អេដស៍ សើស្បែក និងកាមរោគ នៃក្រសួងសុខាភិបាល និងដៃគូការងារថ្នាក់ជាតិផ្សេងៗទៀត ។ ប្រធានបទ និងសារជាក់លាក់មួយនឹងត្រូវស្នើឡើងរៀងរាល់កិច្ចប្រជុំធំដោយបណ្តាញអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា ដោយមានការពិគ្រោះយោបល់ជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងដៃគូការងារផ្សេងៗ ។

អ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍នៅក្នុងខេត្ត-ក្រុងនិមួយៗ និងតំណាងរបស់ដៃគូការងារដែលពាក់ព័ន្ធទាំងអស់ (មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល និងអាជ្ញាធរខេត្ត, ភ្នាក់ងារអង្គការសហប្រជាជាតិ, ដៃគូអភិវឌ្ឍន៍, អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ

។ល។) នឹងត្រូវបានអញ្ជើញមកចូលរួមក្នុងការជួបប្រជុំដ៏សំខាន់នេះ ដែលក្នុងពេលនោះមានសកម្មភាពសំខាន់ៗមួយចំនួនដូចខាងក្រោម នឹងត្រូវអនុវត្តនៅកន្លែងមួយ ដែលមានការឯកភាពពីអាជ្ញាធរខេត្ត-ក្រុង :

- ការដង្ហែរក្បួនរបស់អ្នកផ្ទុកមេរោគអេដស៍
- របាំ និងសិល្បៈសំដែងដោយអ្នកផ្ទុកមេរោគអេដស៍
- ការតាំងពិពណ៌ និងលក់ផលិតផល/សំភារៈដែលផលិតដោយអ្នកផ្ទុកមេរោគអេដស៍ ដែលជាផ្នែកមួយនៃសកម្មភាពរកប្រាក់ចំណូល
- សកម្មភាពរៃអង្គាស

### ៤.២. មណ្ឌលមិត្តជួយមិត្តសំរាប់កុមារ

មណ្ឌលមិត្តជួយមិត្តសំរាប់កុមារ គប្បីថែទាំកុមារដែលឪពុក-ម្តាយបានមករកសេវាផ្សេងៗ នៅមណ្ឌលមិត្តជួយមិត្តសំរាប់មនុស្សពេញវ័យ ។ ទីតាំងមណ្ឌលមិត្តជួយមិត្តសំរាប់កុមារ គួរស្ថិតនៅជិតមណ្ឌលមិត្តជួយមិត្តសំរាប់មនុស្សពេញវ័យ ។ គប្បីរៀបចំបន្ទប់មួយសំរាប់សកម្មភាពមណ្ឌលមិត ្តជួយមិត្តសំរាប់កុមារ ដែលអាចទទួលកុមារបានរហូតដល់ ១០០នាក់ ទៅតាមការប៉ាន់ស្មានចំនួនកុមារដែល មកទទួលការព្យាបាល ។ មណ្ឌលមិត្តជួយមិត្តសំរាប់កុមារ គួររៀបចំឱ្យមានប្រដាប់ប្រដារសំរាប់ក្មេងលេងផងដែរ ។

ក្រុមការងារនៅមណ្ឌលមិត្តជួយមិត្តសំរាប់កុមារ ត្រូវមានសមាជិក ២ នាក់ :

- អ្នកសំរបសំរួល ១រូប ដែលជាបុគ្គលិករបស់មន្ទីរពេទ្យបង្អែក (អ្នកផ្តល់ប្រឹក្សាសំរាប់កុមារ និងមនុស្សជំទង់)
- អ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ ១រូប ដែលជាសមាជិករបស់បណ្តាញអ្នកផ្ទុកមេរោគអេដស៍ថ្នាក់ស្រុកប្រតិបត ្តិ ឬក្រុមគាំទ្រ

សមាជិកក្រុមត្រូវតែងតាំងជាផ្លូវការដោយគណៈកម្មការសំរបសំរួលសេវាថែទាំព្យាបាលបន្តដល់អ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ ថ្នាក់ស្រុកប្រតិបត ្តិ ហើយត្រូវជូនដំណឹងមកមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ។ បញ្ជីឈ្មោះ និងពត៌មាន សំរាប់ទំនាក់ទំនងរបស់សមាជិកនិមួយៗ គប្បីផ្សព្វផ្សាយដល់ដៃគូការងារទាំងអស់ដើម្បីកិច្ចសហប្រតិបត ្តិការទៅអនាគត ។

សមាជិកក្រុម គប្បីទទួលបានការបណ្តុះបណ្តាលនូវជំនាញផ្សេងៗ ដែលចាំបាច់ក្នុងការបំពេញការងារនៅមណ្ឌលមិត្តជួយមិត្តសំរាប់កុមារ ទៅតាមមុខងារ និងតួនាទីរបស់ពួកគេ ។ ការបណ្តុះបណ្តាលនេះ គប្បីធ្វើឡើងដោយអ្នកសំរបសំរួលកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ថ្នាក់ស្រុកប្រតិបត្តិ ដោយមានជំនួយបច្ចេកទេសពីកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត (មន្រ្តីទទួលបន្ទុកការងារថែទាំព្យាបាលបន្ត) និងសហការជាមួយដៃគូការងារផ្សេងៗដែលបំរើការងារនៅក្នុងស្រុកប្រតិបត្តិ ។

ពត៌មានស្តីអំពីទីកន្លែង, ពេលម៉ោងធ្វើការ, និងប្រភេទសេវាដែលផ្តល់ជូនសំរាប់កុមារ គប្បីផ្សព្វផ្សាយជូនដល់ដៃគូការងារទាំងអស់ និង សហគមន៍តាមរយៈបណ្តាញដែលមានស្រាប់ ។

បន្ថែមលើសកម្មភាពដែលមានស្រាប់ មណ្ឌលមិត្តជួយមិត្តសំរាប់កុមារ នឹងផ្តល់ប្រដាប់ប្រដារក្មេងលេង និងល្បែងអប់រំដើម្បីបង្កើតបរិយាកាសល្អមួយដែលធ្វើអោយកុមារចង់ត្រឡប់មកទីនេះមកម្តងទៀត ។

## ៥. ប្រភពធនធានសំរាប់សកម្មភាពមណ្ឌលមិត្តជួយមិត្ត

ខេត្ត-ក្រុងនិមួយៗគប្បីស្វែងរកការជួយឧបត្ថម្ភពីដៃគូផ្សេងៗ ដូចជា អង្គការមិនមែនរដ្ឋាភិបាលដើម្បីឧបត្ថម្ភដល់សកម្មភាពមណ្ឌលមិត្តជួយមិត្ត ។ គំរោងថវិកាសំរាប់សកម្មភាពមណ្ឌលមិត្តជួយមិត្តនៅក្នុងស្រុកប្រតិបត្តិនិមួយៗគប្បីដាក់បញ្ចូលក្នុងគំរោងផែនការសកម្មភាពប្រចាំឆ្នាំរបស់ស្រុកប្រតិបត្តិ ទោះបីជាគំរោងនេះឧបត្ថម្ភដោយអង្គការមិនមែនរដ្ឋាភិបាលក៏ដោយ ។ រៀងរាល់ឆ្នាំអ្នកសំរបសំរួលកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ស្រុកប្រតិបត្តិ នឹងទទួលខុសត្រូវក្នុងការរៀបចំគំរោងផែនការសកម្មភាពមណ្ឌលមិត្តជួយមិត្ត ដោយមានការពិគ្រោះយោបល់ជាមួយគណៈកម្មការសំរបសំរួលការថែទាំព្យាបាលបន្តថ្នាក់ស្រុកប្រតិបត្តិ ដែលនឹងត្រូវបញ្ចូលជាផ្នែកមួយនៃគំរោងផែនការ សកម្មភាពប្រចាំឆ្នាំរបស់ស្រុកប្រតិបត្តិ ។ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នឹងជួយគៀងគរប្រភពធនធាន សំរាប់ឧបត្ថម្ភដល់សកម្មភាពនៃមណ្ឌលមិត្តជួយមិត្ត ។

ផលប្រយោជន៍សំរាប់សមាជិក និងអ្នកស្ម័គ្រចិត្តដែលជាអ្នកផ្ទុកមេរោគអេដស៍នៅមណ្ឌលមិត្តជួយមិត្តនឹងត្រូវផ្តល់ជូនជាការតបស្នងចំពោះការចូលរួមរបស់ពួកគេ ។ ផលប្រយោជន៍ទាំងនេះរួមមាន :

- ការផ្តល់សេវាថែទាំព្យាបាលផ្សេងៗដោយឥតគិតថ្លៃ ដូចជា ការថែទាំព្យាបាលជំងឺឱកាសនិយម និងការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍នៅមន្ទីរពេទ្យបង្អែក
- ការចូលរួមការបណ្តុះបណ្តាល និងការពង្រឹងសមត្ថភាពផ្សេងៗ
- ការផ្តល់ប្រាក់កំរៃប្រចាំខែសំរាប់សមាជិក និងអ្នកស្ម័គ្រចិត្តដែលបំរើការនៅមណ្ឌលមិត្តជួយមិត្ត ដែលឧបត្ថម្ភដោយគំរោងរបស់បណ្តាញអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា និងគំរោងផ្សេងៗរបស់អង្គការក្រៅរដ្ឋាភិបាល

ផលប្រយោជន៍ទាំងនេះ ត្រូវធ្វើឡើងជាផ្លូវការក្នុងរូបភាពជាការថែទាំសុខភាពដែលផ្តល់អោយដោយស្រុកប្រតិបត្តិ និងការចុះកិច្ចសន្យារបស់អ្នកអនុវត្តការងារ ។

ខាងក្រោមនេះ ជាក៏រិតថវិកាស្តង់ដារសំរាប់សកម្មភាពមណ្ឌលមិត្តជួយមិត្ត ដើម្បីណែនាំក្នុងការរៀបចំគំរោង និងទូទាត់ថវិកាសំរាប់សកម្មភាពទាក់ទងនឹងមណ្ឌលមិត្តជួយមិត្ត :

| **មុខចំណាយ** | **ក៏រិត** | **កំណត់សំគាល់** |
|---|---|---|
| អាហារសំរាប់កិច្ចប្រជុំមណ្ឌលមិត្តជួយមិត្ត | US$2 ក្នុងម្នាក់ សំរាប់កិច្ចប្រជុំម្តង | បញ្ជីឈ្មោះអ្នកចូលរួមត្រូវផ្តល់ជាភស្តុតាងបញ្ជាក់ពីការចូលរួមរបស់អ្នកផ្ទុកមេរោគអេដស៍ ។ ចំនួនអ្នកចូលរួមមិនអោយលើសពី ១០០នាក់ សំរាប់ការប្រជុំនិមួយៗចំពោះថវិកាដែលផ្តល់ដោយមជ្ឈមណ្ឌលជាតិ ។ |
| អាហារសំរាប់កិច្ចប្រជុំមណ្ឌលមិត្តជួយមិត្តសំរាប់កុមារ | US$1 ក្នុងម្នាក់ សំរាប់កិច្ចប្រជុំម្តង | បញ្ជីឈ្មោះអ្នកចូលរួមត្រូវផ្តល់ជាភស្តុតាងបញ្ជាក់ពីការចូលរួមរបស់អ្នកផ្ទុកមេរោគអេដស៍ ។ |
| មធ្យោបាយធ្វើដំណើរសំរាប់អ្នកជំងឺមកចូលរួមប្រជុំ | យោងតាមតំលៃជាក់ស្តែង ។ គិតជាមធ្យម US$2 ក្នុងម្នាក់ សំរាប់ការប្រជុំម្តង | បញ្ជីឈ្មោះអ្នកចូលរួមត្រូវផ្តល់ជាភស្តុតាងបញ្ជាក់ពីការចូលរួមរបស់អ្នកផ្ទុកមេរោគអេដស៍ ។ ចំនួនអ្នកចូលរួមមិនអោយលើសពី ១០០នាក់ សំរាប់ការប្រជុំនិមួយៗចំពោះថវិកាដែលផ្តល់ដោយមជ្ឈមណ្ឌល |

| | | |
|---|---|---|
| | | ជាតិ ។ |
| ប្រាក់កំរៃប្រចាំខែរបស់ PLHA ដែលជាអ្នកសំរបសំរួល និងជាជំនួយការនៅមណ្ឌលមិត ្តជួយមិត្ត | US$ 30 ម្នាក់ក្នុង ១ ខែ | ប្រាក់កំរៃនេះ ឧបត្ថម្ភដោយបណ្តាញអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា ឬ អង្គការមិនមែនរដ្ឋាភិបាល ។ ត្រូវមានកិច្ចសន្យាអនុវត្តការងារដែលចុះហត្ថលេខារវាងបណ្តាញអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា ឬ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្ទុកមេរោគអេដស៍ដែលបានចាត់តាំង ។ |
| ថ្លៃធ្វើដំណើរសំរាប់អ្នកស្ម័គ្រចិត ្ត | US$ 10 ម្នាក់ក្នុង ១ ខែ | ប្រាក់ថ្លៃធ្វើដំណើរនេះ ត្រូវឧបត្ថម្ភដោយបណ្តាញអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា ឬ អង្គការមិនមែនរដ្ឋាភិបាល ។ |
| សំភារៈប្រើប្រាស់នៅមណ្ឌលមិត្តជួយមិត្ត | US$ 5 ក្នុង ១ ខែ | ចំនួនទឹកប្រាក់នេះនឹងមិនផ្តល់ជូនទេ ប្រសិនបើមានការផ្តល់អោយ ពីអង្គការមិនមែនរដ្ឋាភិបាល ឬ បណ្តាញអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា ។ |
| ចំណាយផ្សេង | យោងតាមការចំណាយជាក់ស្តែង។ គិតជា មធ្យម US$5 សំរាប់ការប្រជុំម្តង | ឧទាហរណ៏ : ទ័យទានសំរាប់ព្រះសង្ឃដែលនិមន្តមកផ្តល់ការគាំទ្រផ្នែកស្មារតីក្នុងពេលប្រជុំ ។ |

ភ្នំពេញ. ថ្ងៃទី ខែ ឆ្នាំ ២០០៦

បានឃើញ និងឯកភាព

អគ្គនាយកបច្ចេកទេសសុខាភិបាល

វេជ្ជ.ឆេង_លន់

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍

សើស្បែក និងកាមរោគ

វេជ្ជ. មាន_ឈីវុន

# ឧបសម្ព័ន្ធទី ១
# គំរូបញ្ជីឈ្មោះអ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ដែលចូលរួមប្រជុំនៅមណ្ឌលមិត្តជួយមិត្ត

កាលបរិច្ឆេទ

ឈ្មោះខេត្ត

ឈ្មោះស្រុកប្រតិបត្តិ

| ល.រ | ឈ្មោះ | ភេទ | បញ្ជូនមកដោយ (ក្រុមថែទាំតាមផ្ទះ, ក្រុម គាំទ្រ, អង្គការមិនមែនរដ្ឋាភិបាល..) | ចំនួនក្មេងដែលរួមដំណើរជាមួយ (អាយុក្រោម ១៤ឆ្នាំ) | ហត្ថលេខា ឬ ស្នាមមេដៃ |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |
| ១០ | | | | | |
| ១១ | | | | | |
| ១២ | | | | | |
| ១៣ | | | | | |
| ១៤ | | | | | |
| ១៥ | | | | | |
| ១៦ | | | | | |
| ១៧ | | | | | |
| ១៨ | | | | | |
| ១៩ | | | | | |
| ២០ | | | | | |

សំគាល់ : បញ្ជីឈ្មោះត្រូវពិនិត្យ និងចុះហត្ថលេខាដោយអ្នកសំរបសំរួលការងារមណ្ឌលមិត្តជួយមិត្ត ។

## ឧបសម្ព័ន្ធទី ២

## គំរូបញ្ជីឈ្មោះសមាជិកមណ្ឌលមិត្តជួយមិត្ត

ឈ្មោះខេត្ត

ឈ្មោះស្រុកប្រតិបត្តិ

| ល.រ | ឈ្មោះ | ភេទ | អាស័យដ្ឋាន | ចុះសួរសុខទុក្ខដោយ ( ក្រុមថែទាំតាមផ្ទះ,ក្រុមគាំទ្រ, អង្គការមិន មែនរដ្ឋាភិបាល) | ចំនួនក្មេងក្នុងបន្ទុក ( អាយុក្រោម ១៤ឆ្នាំ) | |
|---|---|---|---|---|---|---|
| | | | | | សរុប | មានផ្ទុកមេរោគអេដស៍ |
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |
| ១១ | | | | | | |
| ១២ | | | | | | |
| ១៣ | | | | | | |
| ១៤ | | | | | | |
| ១៥ | | | | | | |
| ១៦ | | | | | | |
| ១៧ | | | | | | |
| ១៨ | | | | | | |
| ១៩ | | | | | | |
| ២០ | | | | | | |

សំគាល់ : បញ្ជីឈ្មោះនេះត្រូវពិនិត្យមើលជាទៀងទាត់ ។ សមាជិកថ្មី គប្បីបន្ថែម និងដកចេញនូវសមាជិកណាដែលទទួលមរណភាព ឬផ្លាស់ប ្តូរទីលំនៅចេញពីស្រុក ។

# ឧបសម្ព័ន្ធទី ៣

# គំរូកំណត់ហេតុកិច្ចប្រជុំនៅមណ្ឌលមិត្តជួយមិត្ត

- កាលបរិច្ឆេទ :
- ចំនួនសមាជិកចូលរួមប្រជុំ : មនុស្សពេញវ័យ និងកុមារ
- អ្នកសំរបសំរួល និងវាគ្មិននៅក្នុងកិច្ចប្រជុំ : ឈ្មោះ, តួនាទី និងទីកន្លែងធ្វើការ
- សកម្មភាពប្រជុំ :
  - ប្រធានបទដែលត្រូវពិភាក្សាក្នុងកិច្ចប្រជុំ
    - គោលបំណងរបស់ប្រធានបទនិមួយៗ
    - ចំណុចសំខាន់នៃប្រធានបទនិមួយៗ
    - វិធីសាស្ត្រដែលប្រើប្រាស់ក្នុងកិច្ចប្រជុំ
  - សកម្មភាពរបស់មណ្ឌលមិត្តជួយមិត្តសំរាប់កុមារ
- សកម្មភាពផ្សេងៗ

  ឧទាហរណ៍

    - ការពិនិត្យសុខភាព : តើមានអ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ប៉ុន្មាននាក់ដែលបានពិនិត្យសុខភាព ឬបានតាមដានរកជំងឺឱកាសនិយម ឬតាមដានការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ?
    - បញ្ជូនទៅសេវាថែទាំផ្សេងៗ : តើមានអ្នកផ្ទុកមេរោគអេដស៍-អ្នកជំងឺអេដស៍ប៉ុន្មាននាក់ដែលបានបញ្ជូនទៅសេវាព្យាបាលជំងឺរបេង, សេវាកាត់បន្ថយការចំលងមេរោគអេដស៍ពីឪពុកម្ដាយទៅកូន ។ល។
- សេចក្តីសន្និដ្ឋាន
  - តើប្រធានបទដែលលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំឆ្លើយតបទៅនឹងតំរូវការរបស់អ្នកផ្ទុកមេរោគអេដស៍ដែលបានមកចូលរួមដែរឬទេ ?
  - បញ្ហាផ្សេងៗ, ដំណោះស្រាយ, និងអនុសាសន៍ដែលបានលើកឡើងក្នុងពេលប្រជុំ
- ការកំណត់កាលបរិច្ឆេទ និងប្រធានបទសំរាប់កិច្ចប្រជុំលើកក្រោយ

# ឧបសម្ព័ន្ធទី ៤

## គំរូប្លង់អាគារ MMM និង សេវា OI/ART

